ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

លេខ :

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០០៧

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកំណត់អត្រាសួយសារលើតម្លៃធនធាន
## រ៉ែលោហៈ អលោហៈ (ធនធានរ៉ែឧស្សាហកម្ម) រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្តាលមានតម្លៃ
## ថ្មសំអាង និងធនធានរ៉ែផ្នូនៈរឹង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញបទបញ្ជារបស់រាជរដ្ឋាភិបាល លេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។

## សម្រេច

**ប្រការ ១.-**

សម្បទានិក ដែលមានអាជ្ញាប័ណ្ណធនធានរ៉ែទាំងអស់ លើកលែងតែអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ និង អាជ្ញាប័ណ្ណស្វែងរុករក ត្រូវបង់ចូលថវិការដ្ឋ ក្នុងកំឡុងពេល០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការមុននឹងដឹកជញ្ជូនធនធានរ៉ែចេញពីការដ្ឋាន ឬរោងចក្រនូវសួយសារលើតម្លៃធនធានរ៉ែលោហៈ ឬធនធានរ៉ែអលោហៈ(ធនធានរ៉ែឧស្សាហកម្ម) រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្តាលមានតម្លៃ ថ្មសំអាង និងរ៉ែឥន្ធនៈរឹង ដែលទាញយកបាន នៅគណនីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅធនាគារជាតិ ឬសាខាធនាគារខេត្ត-ក្រុង ។

**ប្រការ ២.-**

សួយសារលើតម្លៃធនធានរ៉ែលោហៈ ធនធានរ៉ែអលោហៈ(ធនធានរ៉ែឧស្សាហកម្ម) រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្តាលមានតម្លៃ ថ្មសំអាង និងធនធានរ៉ែឥន្ធនៈរឹង ដែលទាញយកបាន ត្រូវកំណត់អត្រាសួយសារដូចខាងក្រោម:

| | | អត្រាសួយសារ | |
|---|---|---|---|
| ១. | **ធនធានរ៉ែលោហៈ** | សំរាប់ផ្គត់ផ្គង់ដល់រោងចក្រហើយដែលរោងចក្រនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់សម្បទានិកមានអាជ្ញាប័ណ្ណធនធានរ៉ែ | សំរាប់គោលបំណងពាណិជ្ជកម្ម |
| | - អង់ទីម៉ូនី (Sb) | | |
| | - ក្រូម (Cr) | | |
| | - ដែក (Fe) | | |
| | - ម៉ង់កាណែស (Mn) | ២.៥ % - ៣.៥% | |
| | - ម៉ូលីបដែន (Mo) | នៃតម្លៃលក់ផលិតផលដោយផ្ទែក | ៤% - ៥% |

| | | | |
|---|---|---|---|
| | - តង់ស្តែន (W) | តាមតម្លៃនៅលើទីផ្សារអន្តរជាតិ | |
| | - អាលុយមីណា/អាលុយមីញ៉ូម | | |
| | - ទង់ដែង (Cu) | | |
| | - ស័ង្កសី (Zn) | | |
| | - សំណប៉ាហាំង (Sn) | | |
| | - សំណ (Pb ) | | |
| | - មាស (Au) | ២.៥ % - ៣.៥%<br>នៃតម្លៃលក់ផលិតផលដោយផ្អែក<br>តាមតម្លៃនៅលើទីផ្សារអន្តរជាតិ | ៤% - ៥% |
| | - ប្លាកទីនញ៉ូម (Pt) | | |
| | - ប្រាក់ (Ag) | | |
| | - អ៊ីមីនីត (Ti) និង | | |
| | - ធនធានរ៉ែលោហៈផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា | | |
| ២. | **ធនធានរ៉ែអលោហៈ (ធនធានរ៉ែឧស្សាហកម្ម)** | | |
| | - ដីឥដ្ឋធ្វើស៊ីម៉ង់ត៍ | ០.១០ដុល្លារអាមេរិក/តោនស៊ីម៉ង់ត៍ដែលផលិតបាន | ០.១០ដុល្លារអាមេរិក/តោន |
| | - កៅឡាំង | ១.២០ដុល្លារអាមេរិក/តោននៃផលិតផលសំរេច | ១.២០ដុល្លារអាមេរិក/តោន |
| | - ថ្មកំបោរ | ០.២០ដុល្លារអាមេរិក/តោនស៊ីម៉ង់ត៍ដែលផលិតបាន | ១.៥០ដុល្លារអាមេរិក/តោន |
| | - ថ្មហ្វូស្វ័រីត | ១.២០ដុល្លារអាមេរិក/តោនជីហ្វូសស្វាតដែលផលិតបាន | ១.២០ដុល្លារអាមេរិក/តោន |
| | - ខ្សាច់ស៊ីលីស | ១.៥០ដុល្លារអាមេរិក/តោនខ្សាច់ឆៅ( មិនទាន់កែច្នៃ) | ១.៥០ដុល្លារអាមេរិក/តោន |
| | - អំបិល | ០.៥០ដុល្លារអាមេរិក/ តោនអំបិល | ០.៥០ដុល្លារអាមេរិក/តោន |
| ៣. | **ត្បូងថ្មមានតម្លៃ ពាក់កណ្តាលមានតម្លៃ ថ្មសំអាង** | | |
| ក. | **ត្បូងថ្មមានតម្លៃ** | | |
| | - ពេជ្រ | | |
| | - ត្បូងទទឹម | | |
| | - ត្បូងកណ្ដៀង | ១៥ % នៃតម្លៃលក់ផលិតផល<br>នៅលើទីផ្សារអន្តរជាតិ | |
| | - មរកត និង | | |
| | - រ៉ែត្បូងថ្មទាំងឡាយដែលមានគុណភាពប្រ ហាក់ ប្រហែលគ្នា | | |
| ខ. | **ត្បូងថ្មពាក់កណ្តាលមានតម្លៃ** | | |
| | - ត្បូងសៀកុន(Zircon ) | | |
| | - អាមេទីស (Amethyst ) | ១៥ % នៃតម្លៃលក់ផលិតផល<br>នៅលើទីផ្សារអន្តរជាតិ | |
| | - តូប៉ាស | | |
| | - រ៉ែត្បូងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែលគ្នា | | |
| គ. | **ថ្មសំអាង** | | |

| | | | |
|---|---|---|---|
| | ហេ្សត.ថ្មម៉ាប.ប៉ាហ្គោឌីត.ក្រានីត. កាល់សេដូន. អាស្វីត. អូប៉ាល់ធម្មតា. អាហ្គាត. ម៉ាឡាស៊ីក. ឈើថ្ម . ថ្មថ្លើមអណ្តើក និងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែល ។ | ១៥ % នៃតម្លៃលក់ផលិតផល នៅលើទីផ្សារអន្តរជាតិ | |
| ៤. | **ធនធានរ៉ែឥន្ធនៈរឹង** | | |
| | - ធ្យូងថ្ម | ៧ % នៃតម្លៃលក់ផលិតផល នៅលើទីផ្សារអន្តរជាតិ | |
| | - ធ្យូងភក់ | | |

## ប្រការ ៣.-

ក្នុងករណីធនធានរ៉ែផ្សេងទៀតដែលត្រូវបានរកឃើញហើយមិនបានកំណត់អត្រាសួយសារនៅក្នុងប្រកាសនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នឹងធ្វើការសិក្សា និងកំណត់បន្ថែមក្នុងប្រកាសអន្តរក្រសួងនៅពេលក្រោយ ។

## ប្រការ ៤.-

ផ្អែកលើមូលដ្ឋានគំរោងចំណូលដែលបានកត់ត្រាក្នុងសៀវភៅថវិការបស់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្ត-ក្រុង គណៈកម្មការចំរុះដែលរួមមាន តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាប្រធាន និងតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក ត្រូវចុះទៅធ្វើការត្រួតពិនិត្យសកម្មភាពផលិតកម្មអាជីវកម្មតាមការដ្ឋាន ឬរោងចក្រនីមួយៗ ដើម្បីគណនានូវចំនួនទឹកប្រាក់សួយសារដែលសម្បទានិកត្រូវបង់ពិតប្រាកដ ។

## ប្រការ ៥.-

ចំណូលពីសួយសារលើតម្លៃធនធានរ៉ែលោហៈ ធនធានរ៉ែអលោហៈ(ធនធានរ៉ែឧស្សាហកម្ម) រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្តាលមានតម្លៃ ថ្មសំអាង និងធនធានរ៉ែឥន្ធនៈរឹង ត្រូវបានបែងចែក និងបង់ចូល ថវិការដ្ឋចំនួន ៨០ (ប៉ែតសិប)ភាគរយ ថវិកាខេត្ត-ក្រុងចំនួន២០(ម្ភៃ)ភាគរយ និងអនុញ្ញាតឱ្យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដកវិញ ចំនួន១០(ដប់)ភាគរយ នៃថវិការដ្ឋនេះ សំរាប់ចំណាយក្នុងការសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ និងធនធានរ៉ែ ។

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការកំណត់ និងគ្រោងខ្ទង់ចំណូលនេះនៅពេលធ្វើការពិភាក្សាថវិកាប្រចាំឆ្នាំនីមួយៗដោយកត់ត្រាដូចខាងក្រោម :

- ៨០ភាគរយ នៃចំណូលពីការបង់សួយសារលើតម្លៃធនធានរ៉ែលោហៈ ឬធនធានរ៉ែអលោហៈ (ធនធានរ៉ែឧស្សាហកម្ម ) រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្តាលមានតម្លៃ ថ្មសំអាង និងធនធានរ៉ែឥន្ធនៈរឹង ត្រូវកត់ត្រាក្នុងគំរោងចំណូលរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលនៅថ្នាក់ខេត្ត-ក្រុង (ថវិការដ្ឋ) ត្រង់ជំពូក៧២ គណនី៧២០ អនុគណនី៧២០៤ (សម្បទានពីរ៉ែ) ហើយខ្ទង់ចំណូលនេះ នឹងត្រូវបែងចែកលំអិតនៅក្នុងសៀវភៅថវិការបស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរបស់ខេត្ត-ក្រុង នីមួយៗ ។
- ១០ភាគរយ នៃចំណូលថវិការដ្ឋនេះ ត្រូវកត់ត្រាក្នុងគំរោងចំណាយរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលនៅថ្នាក់រដ្ឋបាលកណ្តាល ត្រង់ជំពូក៦១ គណនី៦១៧ អនុគណនី៦១៧១ (ការសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ និងធនធានរ៉ែ) ។

- ២០ភាគរយ នៃចំណូលពីការបង់សួយសារលើតម្លៃធនធានរ៉ែលោហៈ ធនធានរ៉ែអលោហៈ (ធនធានរ៉ែឧស្សាហកម្ម) រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្ដាលមានតម្លៃ ថ្មសំអាង និងធនធានរ៉ែឥន្ធនៈរឹង ត្រូវកត់ត្រាក្នុងតំរោងចំណូលរបស់សាលាខេត្ត-ក្រុង(ថវិកាខេត្ត-ក្រុង) ត្រង់ជំពូក ៧២ គណនី៧២០ អនុគណនី៧២០៤(សម្បទានពីរ៉ែ) ហើយខ្ទង់ចំណូលនេះ នឹងត្រូវបែងចែកលំអិតនៅក្នុងសៀវភៅថវិការបស់ខេត្ត-ក្រុងនីមួយៗ ។
- មួយផ្នែកនៃចំណូលថវិការដ្ឋខាងលើនេះ ត្រូវបានអនុញ្ញាតឱ្យដកយកទៅចំណាយប្រើប្រាស់សំរាប់ផ្ដល់ការលើកទឹកចិត្តដល់ មន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ តាមការកំណត់ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោយពីបានការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាល ។

## ប្រការ ៦.-

រាល់ការកំណត់តម្លៃលក់ធនធានរ៉ែលោហៈ ធនធានរ៉ែអលោហៈ(ធនធានរ៉ែឧស្សាហកម្ម) រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្ដាលមានតម្លៃ ថ្មសំអាង និងធនធានរ៉ែឥន្ធនៈរឹង ត្រូវធ្វើឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងសម្បទានិកដោយផ្អែកតាមថ្លៃនៅទីផ្សារអន្តរជាតិនៅរៀងរាល់ចុងត្រីមាសនីមួយៗក្នុងគោលដៅកំណត់ការបង់សួយសារ ។

## ប្រការ ៧.-

មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ស្ដីពីសភាពការណ៍អនុវត្តកាតព្វកិច្ចចំណូលសួយសារលើតម្លៃធនធានរ៉ែលោហៈ ធនធានរ៉ែអលោហៈ(ធនធានរ៉ែឧស្សាហកម្ម) រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្ដាលមានតម្លៃ ថ្មសំអាង និងធនធានរ៉ែឥន្ធនៈរឹង ប្រចាំខែជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ) ដោយថតចម្លងភ្ជាប់មកជាមួយនូវសលាកប័ត្របង់ចំណូលថវិកាទាំងអស់ដែលអនុវត្តបាន ។

## ប្រការ ៨.-

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវធ្វើអាណត្តិបើកប្រាក់សំរាប់ចំណាយលើការសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ និងធនធានរ៉ែនូវទឹកប្រាក់ដែលមានសមាមាត្រសមមូលទៅនឹងចំនួនទឹកប្រាក់សរុបនៃសលាកប័ត្របង់ចំណូលរបស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ហើយសលាកប័ត្របង់ចំណូលនេះ ត្រូវភ្ជាប់មកជាមួយនូវលិខិតយុត្តិការ នៅពេលមកចុះទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ។

## ប្រការ ៩.-

សួយសារលើតម្លៃធនធានរ៉ែលោហៈ ធនធានរ៉ែអលោហៈ(ធនធានរ៉ែឧស្សាហកម្ម) រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្ដាលមានតម្លៃ ថ្មសំអាង និងធនធានរ៉ែឥន្ធនៈរឹង ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែ រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុនដែលមានពីមុនហើយផ្ទុយនឹងប្រកាសនេះត្រូវកែសម្រួលឱ្យស្របតាមប្រកាសនេះ ។

ប្រការ ១០.-

អង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចំណុះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងសម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ ១១.-

ប្រកាសនេះ មានប្រសិទ្ធភាព និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

កន្លែងទទួល :

- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ខេត្ត-ក្រុង
  (ដើម្បីជូនជ្រាប)
- ដូចប្រការ ១០
  (ដើម្បីអនុវត្ត)
- កាលប្បវត្តិ-ឯកសារ